Australian Government

Department of Home Affairs

# ទំនាក់ទំនងដើម្បីសម្រួលដល់ការតាំងទីលំនៅថ្មី និងជំនួយសម្រាប់ការឆ្លងកាត់ការផ្លាស់ប្តូរ (SETS)

## ការកែប្រែសេវាកម្មដោយសារកូវីដ-19

ជំនួយភ្ជាប់ទំនាក់ទំនងដើម្បីសម្រួលដល់ការមកតាំងទីលំនៅថ្មីនិងជំនួយសម្រាប់ការឆ្លងកាត់ការផ្លាស់ប្តូរ នៅតែមានបន្តសម្រាប់អតិថិជនក្នុងអំឡុងពេលមានកូវីដ-19 រាតត្បាត។
តែរបៀបផ្តល់សេវានេះអាចមានការកែប្រែអាស្រ័យទៅលើឱវាទផ្លូវការវិស័យ  សុខាភិបាល។

បច្ចុប្បន្ននេះ ស្ថាប័នផ្តល់សេវាកម្មជាច្រើនកំពុងជួយអតិថិជនរបស់ខ្លួនដោយប្រើសេវាទូរស័ព្ទ ឬតាមអនឡាញ។
ក្នុងករណីខ្លះ ស្ថាប័នផ្តល់សេវាអាចជួបអតិថិជនផ្ទាល់ក្នុងករណីបន្ទាន់ ឬក៏បើពុំអាចធ្វើតាមអនឡាញបាន។

ស្ថាប័នផ្តល់សេវាមានលទ្ធភាពរកសេវាបកប្រែសម្រាប់អតិថិជនដែលមិនសូវចេះនិយាយអង់គ្លេស។

ស្វែងយល់អំពី **កូវីដ-19 និងរោគសញ្ញារបស់វា** ។

ចូរសិក្សាយល់ដឹងអំពី កូវីដ-19 និងរោគសញ្ញារបស់វា។

### តើកម្មវិធី  SETS ជាអ្វី ?

ជំនួយភ្ជាប់ទំនាក់ទំនងដើម្បីសម្រួលដល់ការមកតាំងទីលំនៅថ្មីនិងជំនួយសម្រាប់ការឆ្លងកាត់ការផ្លាស់ប្តូរ (The Settlement Engagement Transition Support (SETS) )
គឺជាកម្មវិធីថ្នាក់ជាតិសម្រាប់ដោះស្រាយសេចក្តីត្រូវការរបស់ជនអន្តោប្រវេសន៍ដែលមានសិទ្ធិក្នុងការតាំងទីលំនៅថ្មី។ កម្មវិធីនេះសំដៅទៅលើការជួយឲ្យកាន់តែប្រសើរនូវការចូលរួមក្នុងវិស័យសង្គមនិងសេដ្ឋកិច្ច ហើយនិងជួយឲ្យមានការផ្សារភ្ជាប់ក្នុងសហគមន៍។

កម្មវិធីនេះមានពីរផ្នែក ៖

- *SETS – សេវាកម្មសម្រាប់អតិថិជន* ផ្តល់ជូនអតិថិជននូវព័ត៌មានទាក់ទងនិងការមកតាំងទីលំនៅថ្មី ឱវាទ ការតស៊ូមតិ ហើយនិងជំនួយក្នុងការរកសេវាពាក់ព័ន្ធនានា។
- *SETS – ការកសាងសមត្ថភាពសហគមន៍* ជួយទ្រទ្រង់ក្រុមសហគមន៍និងអង្គការថ្មីៗ ប្រយោជន៍ឲ្យក្រុមសហគមន៍ និងអង្គការទាំងនេះ ជួយទំនុកបម្រុងសហគមន៍របស់ខ្លួនដើម្បីធានាឲ្យបាននូវលទ្ធផលវិជ្ជមានជាយូរអង្វែងនៃការមកតាំងទីលំនៅថ្មី ។

### តើ SETS ផ្តល់សេវាកម្មអ្វីខ្លះ ?

ស្ថាប័នផ្តល់សេវា SETS អាចជួយលោកអ្នកដោយផ្តល់ព័ត៍មាននិងឱវាទក្នុងវិស័យមួយចំនួន រួមទាំងសិក្ខាធិការនិងការបណ្តុះបណ្តាល ដោយជួយសម្រួលឲ្យអ្នកទទួលបានជំនាញភាសាអង់គ្លេសនិងសេវាភាសានានា ការងារ លំនៅដ្ឋាន សុខាភិបាលនិងសុខុមាលភាព ការគាំពារគ្រួសារនិងសង្គម ការដឹកជញ្ជូន ការចូលរួមក្នុងសង្គម ហើយនិងវិស័យច្បាប់។

ប្រភេទនៃសកម្មភាពទាំងនេះអាចមានជាឧទាហរណ៍ ក្លឹបនៃការធ្វើលំហាត់នៅផ្ទះ កម្មវិធីបង្ហាត់ជំនាញបើកឡាន ក្រុមសុខភាពស្ត្រីនិងការយល់ដឹង ឱកាសក្នុងការហាត់និយាយភាសាអង់គ្លេស វគ្គត្រៀមធ្វើការដោយរួមទាំងរបៀបរកការងារធ្វើនៅប្រទេស អូស្ត្រាលី ចំណេះក្នុងការធ្វើសម្ភាសន៍ ហើយនិងការសរសេរប្រវត្តិរូប។

ជំនួយក៍អាចផ្តល់ឲ្យទៅក្រុមសហគមន៍ ឬប្រធានសហគមន៍ដើម្បីជួយលោកអ្នកក្នុងការជួយសមាជិកសហគមន៍របស់ខ្លួន។

ស្ថាប័នផ្តល់សេវាក៍អាចបញ្ជូនលោកអ្នកឲ្យទៅជួបស្ថាប័នផ្តល់សេវាដទៃទៀតដើម្បីឲ្យគេជួយក្នុងរឿងដែលលោកអ្នកជួបប្រទះ។

### តើខ្ញុំមានសិទ្ធិទទួលសេវាទាំងនេះឬទេ?

SETS - សកម្មភាពសេវាសម្រាប់អតិថិជន ត្រូវបានផ្តល់ជូនទៅជនអន្តោប្រវេសន៍ក្នុងប្រាំឆ្នាំដំបូងនៃជីវិតរបស់គេនៅប្រទេសអូស្ត្រាលី តាមប្រភេទដូចតទៅនេះ ៖

- អ្នកចូលមកដោយសារកត្តាមនុស្សធម៌
- ជនអន្តោប្រវេសន៍ដែលមកដោយសារក្រុមគ្រួសារ ហើយដែលមានកម្រិតភាសាអង់គ្លេសទាប
- អ្នកនៅក្នុងបន្ទុករបស់ជនអន្តោប្រវេសន៍ដែលមានជំនាញនៅជនបទ ហើយដែលមានកម្រិតភាសាអង់គ្លេសទាប
- ជនស្នាក់នៅបណ្តោះអាសន្នដែលត្រូវបានជ្រើសរើសមួយចំនួន (អ្នកកាន់ទិដ្ឋាការបណ្តោះអាសន្នក្នុងភាពជាគូដណ្តឹងនិងគូជីវិត ហើយនិងជននៅក្នុងបន្ទុករបស់គេ) ដែលនៅទីជនបទហើយមានកម្រិតភាសាអង់គ្លេសទាប។

SETS – ការកសាងសមត្ថភាពសហគមន៍ សំដៅទៅលើក្រុមអនិកជនជាក់លាក់ដែលទើបបង្ហាញមុខមាត់ និងទើបមកដល់ថ្មី៖

- សហគមន៍ ប្រធានសហគមន៍ និងតំណាងរបស់សហគមន៍ទើបបង្ហាញមុខមាត់ និងទើបមកដល់ថ្មី និង
- អង្គការដែលមានសមាសភាពស្មុចស្មើង

### តើខ្ញុំអាចស្វែងរកព័ត៍មានថែមទៀតអំពីសេវាកម្ម SETS ដោយរបៀបណា ?

ដើម្បីរកស្ថាប័នផ្តល់សេវា SETS ក្នុងតំបន់របស់លោកអ្នក សូមចូលទៅ **ទីនេះ** ហើយបើកតំណភ្ជាប់ទៅមើលតារាងនៃស្ថាប័នផ្តល់សេវាទាំងឡាយ។ ពេលបានឈ្មោះនិងអាសយដ្ឋាននៃស្ថាប័នផ្តល់សេវាណាមួយហើយ សូមស្វែងរកមើលគេហទំព័ររបស់ស្ថាប័នផ្តល់សេវានោះនៅក្នុងអ៊ិនធើណិត។ ស្ថាប័នផ្តល់សេវា SETS នឹងមានព័ត៍មាននៅក្នុងគេហទំព័ររបស់គេអំពីរបៀបដែលប្រសើរបំផុតក្នុងការទាក់ទង។